- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតំរូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជា នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម គាប់ពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៨ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ខេត្ត-ក្រុង និង ឯកឧត្តម ស ខេង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★ ★ ★

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៨

## សេចក្តីសំរេចលេខ ៨៥ សសរ

## ស្តីពីការផ្ទេរសិទ្ធិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតំរូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជា រដ្ឋមន្ត្រីស្តីទី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិជំនួសឯកឧត្តម **ហោ ណាំហុង** ដែល

ត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ក្រសួងផលប់ពេលឯកឧត្តមអញ្ជើញវិលត្រឡប់មកកាន់ព្រះរាជាណាចក្រវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អ៊ឹម ឈុនលឹម ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៨

**សេចក្តីសម្រេចលេខ ៤៦ សសរ**

**ស្តីពីការបន្ថែមសមាសភាព នៃគណៈកម្មាធិការទទួលជនភៀសខ្លួន និងសមាហរណកម្មក៏លាំងផ្តាច់ខ្លួន**

★★★

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសេចក្តីសម្រេចលេខ ៤៣ សសរ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការទទួលជនភៀសខ្លួន និង សមាហរណកម្មកំលាំងផ្តាច់ខ្លួន
- តាមការចាំបាច់របស់សង្គមជាតិ

**សម្រេច**

ប្រការ ១ : ត្រូវបានបន្ថែមសមាសភាពនៅក្នុងប្រការ១ នៃសេចក្តីសម្រេចលេខ ៤៣ សសរ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីបង្កើតគណៈកម្មាធិការទទួលជនភៀសខ្លួន និងសមាហរណកម្មកំលាំងផ្តាច់ខ្លួន :

-ឯកឧត្តម អ៊ុង គឹមអន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក